# សេចក្តីផ្តើម

## ធ្វើយ៉ាងណាទើបបាត់ក្រោធ ?

ព្រះពុទ្ធសាសនា ជាសាសនានៃមេត្តាករុណា ។ ព្រះសម្មាសម្ពុទ្ធជាអង្គម្ចាស់ ព្រះអង្គមាននូវព្រះគុណដ៏ធំ-ធេងដែលចែកទៅជាច្រើនផ្នែក ក្នុងនោះមានផ្នែកមួយដ៏ធំគឺព្រះមហាករុណាគុណហ្នឹងឯង ។ ពុទ្ធបរិស័ទគ្រប់គ្នាបានទទួលការទូន្មានអប់រំឱ្យមាននូវមេត្តាករុណា ឱ្យចេះមានការជួយទំនុកបម្រុងគ្នាដោយកាយវាចា និងមានទឹកចិត្តប្រាថ្នាល្អ ។ សូម្បីតែមិនបានធ្វើនូវអ្វីដទៃ ក៏ត្រូវឱ្យចម្រើនមេត្តាផ្សាយដល់ពពួកមនុស្ស រហូតដល់សត្វទាំង-ពួងផ្សេងទៀត សូមឱ្យរស់នៅជាសុខ ប្រាសចាកភ័យនិងពៀរគ្រប់គ្នាទាំងអស់ ។



យ៉ាងណាក៏ដោយ **មេត្តា** រមែងមានគូប្រឆាំងដ៏សំខាន់មួយគឺ **កោធៈ** សេចក្តីខឹងក្រោធ ។ សេចក្តីក្រោធជាសត្រូវដែលចាំតែរារាំងមិនឱ្យមេត្តាកើតឡើងបាន ។ មនុស្សខ្លះជាអ្នកច្រើនដោយសេចក្តីក្រោធ កាលដែលមានសេចក្តីខឹងក្រោធកើតឡើងហើយ ក៏ត្រូវធ្វើនូវអ្វីឱ្យមានភាពរមុាំងរម៉ោកកើតឡើង គឺដូចជាបោកបោះនូវរបស់ផ្សេងៗ ឬពាក្យសម្តីនិយាយខ្លាំងៗខ្លាំងៗជាដើម មានរហូតដល់ថ្នាក់ធ្វើឱ្យវិនាសសម្បត្តិទ្រព្យធំដុំទៀតផង ។ បើធ្វើអ្វីមិនបានទេ ក៏គង់នៅស្ងៀមមិននិយាយស្តី ធ្វើមុខក្រញូវ នៅដោយការក្តៅរំងំក្នុងចិត្ត គឺសម្ងំដុតចិត្តខ្លួនឯង។ ក្នុងវេលានោះមេត្តាគេចខ្លួនបាត់ទៅហើយ មិនដឹងជាទៅពួនក្នុងទីណានោះទេ មិនព្រមចេញមុខមកសោះ ចំណែកសេចក្តីក្រោធវិញ ទាំងដែលមិនត្រូវការផងនោះ គឺវាមិនព្រមគេចចេញទៅណាឡើយ ទោះជាមានពេលខ្លះដឹងថាលំបាកហើយបាបទៀត តែក៏មិនដឹងថា ត្រូវបណ្តេញ ឬកម្ចាត់វាចោលឱ្យអស់ទៅយ៉ាងណាដែរ ។

បណ្ឌិតលោកដឹងចិត្តមនុស្សដែលក្រោធថា មានសភាពបែបណាហើយនោះ ទើបលោកខំព្យាយាមជួយដោយការប្រាប់វិធីផ្សេងៗ សម្រាប់រម្ងាប់សេចក្ដីក្រោធ ។

វិធីរម្ងាប់សេចក្ដីក្រោធទាំង ១២ មុខក្នុងសៀវភៅនេះ មានប្រយោជន៍មិនចំពោះតែមនុស្សដែលច្រើនដោយសេចក្ដីក្រោធប៉ុណ្ណឹងទេ គឺជាគតិដល់មនុស្សគ្រប់គ្នា ជួយឱ្យឃើញទោសនៃសេចក្ដីក្រោធ និងជួយឱ្យឃើញគុណរបស់មេត្តាកាន់តែក្រៃលែងឡើងទៀតផង ។

ដូច្នេះសូមពុទ្ធបរិស័ទ ពិចារណា សិក្សាអប់រំចិត្តតាមការណែនាំរបស់បណ្ឌិត ក្នុងវិធីសម្រាប់រម្ងាប់សេចក្ដីក្រោធទាំង ១២ មុខនៅក្នុងសៀវភៅនេះ ហើយកាន់យកនូវប្រយោជន៍ពិតប្រាកដ រៀងៗ ខ្លួនទៅហោង ។

ភ្នំពេញខែជេស្ឋ ព.ស.២៥៤៧

**សេចក្ដីសុខចិត្តជាពរដ៏ប្រសើរ**



# ១-ពិចារណា
# ដល់ភាពសៅហ្មងនៃបុគ្គលក្រោធ

គប្បីពិចារណាក្នុង ៣ ចំណុចនេះ :

១.ប្រដៅខ្លួនឯងឱ្យនឹកឃើញថា ព្រះពុទ្ធជាម្ចាស់របស់យើង ទ្រង់មានព្រះមហាករុណាទិគុណ ព្រះអង្គទូន្មានពុទ្ធបរិស័ទឱ្យជាមនុស្សមានមេត្តា តែបែរជាយើងក្រោធហើយ មិនរម្ងាប់សេចក្ដីក្រោធ នេះជាការមិនបដិបត្តិតាមពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះអង្គ ជាការមិនគោរពព្រះសាស្ដា គឺថាយើងមិនសមធ្វើជាសិស្សរបស់ព្រះអង្គឡើយ ដូច្នេះ យើងត្រូវតែប្រញាប់ធ្វើខ្លួនឱ្យសមជាសិស្សរបស់ព្រះពុទ្ធ និងឱ្យជាពុទ្ធបរិស័ទដ៏ល្អតទៅ ។

២.ព្រះពុទ្ធជាម្ចាស់ត្រាស់ប្រដៅថា មនុស្សដែលក្រោធមុនគេគឺចាត់ថាអាក្រក់ហើយ ចំណែកមនុស្សដែល

មិនមានសតិភ្ញាក់រលឹក វង្វេងខឹងក្រោធតបទៅគេវិញ គឺជាការសាងនូវសេចក្តីអាក្រក់ឱ្យវែងឆ្ងាយ ឬឱ្យរឹតតែច្រើនឡើង នេះចាត់ថា អាក្រក់ជាងអ្នកដែលក្រោធមុននោះទៅទៀត ដូច្នេះ យើងជាសិស្សរបស់ព្រះពុទ្ធ យើងត្រូវសិក្សាថា « អាត្មាអញ កុំជាមនុស្សអាក្រក់ ទាំងកុំជាមនុស្សអាក្រក់ជាងគេទៀតឡើយ » ។

៣-ព្រះពុទ្ធជាម្ចាស់ទ្រង់ទូន្មានជាបន្តថា គេក្រោធមករកយើង យើងមិនក្រោធតបទៅគេវិញ យ៉ាងនេះហៅថា ឈ្នះសង្គ្រាមដែលឈ្នះបានដោយកម្រ ។

កាលដឹងទាន់ថា អ្នកដទៃគេខឹងក្រោធមកហើយ យើងមានសតិរម្ងាប់ចិត្តបាន មិនខឹងក្រោធតប ឈ្មោះថា ជាអ្នកធ្វើប្រយោជន៍ឱ្យបានសម្រេចទាំងពីរខាង គឺខាងអ្នកដទៃ និងខាងខ្លួនឯង ព្រោះដូច្នោះ យើងជាពុទ្ធបរិស័ទ ចូរកុំធ្វើខ្លួនឱ្យជាអ្នកចាញ់សង្គ្រាម ចូរជាអ្នកឈ្នះសង្គ្រាម និងជាអ្នកសាងប្រយោជន៍ កុំជាអ្នកសាងសេចក្តីវិនាសហិនហោចឡើយ ។



## ២-ពិចារណា
## ទោសនៃសេចក្តីក្រោធ

ក្នុងចំណុចនេះព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្តែងទុកមកច្រើនណាស់ ដូចជា :

បុគ្គលក្រោធរមែងមានពណ៌សម្បុរមិនស្អាត ដេកជាទុក្ខ បែកមិត្ត អស់យស ។ល។ បុគ្គលអ្នកក្រោធមិនដឹងថាសេចក្តីក្រោធនោះ គឺជាភ័យដែលកើតឡើងក្នុងខ្លួនទេ។ បុគ្គលអ្នកក្រោធខឹង រមែងមិនដឹងប្រយោជន៍ រមែងមិនឃើញធម៌ ។ បុគ្គលដែលសេចក្តីក្រោធគ្របសង្កត់មានតែភាពងងឹតប៉ុណ្ណោះ ។ បុគ្គលអ្នកក្រោធធ្វើនូវអំពើអាក្រក់បានដោយងាយហាក់ដូចជាធ្វើអំពើល្អ ប៉ុន្តែលុះ

ដល់ក្រោយមក កាលបើបាត់ក្រោធហើយ ក៏មានការក្តៅក្រហាយស្តាយក្រោយដូចជាត្រូវភ្លើងឆេះ ។

មនុស្សក្រោធ រមែងសម្តែងនូវមុខក្រញូវជាដំបូង ដូចភ្លើងមុននឹងឆេះរមែងញុំាងផ្សែងឱ្យកើតឡើងសិន លុះដល់កាលណា សេចក្តីក្រោធសម្តែងនូវតេជានុភាពហើយ កាលនោះ មនុស្សក្រោធ រមែងមិនខ្លាចអ្វីឡើយ ការខ្មាសអៀនក៏មិនមាន សេចក្តីគោរពក៏មិនមាន គេរមែងធ្វើនូវអំពើវិនាសផ្សេងៗ ដូចជាភ្លើងឆេះព្រៃឬឆេះភូមិអ្នកស្រុកដូច្នោះឯង។

មនុស្សក្រោធសម្លាប់ឪពុក សម្លាប់ម្តាយរបស់ខ្លួនឯងក៏បាន សម្លាប់ព្រះអរហន្តក៏បាន សម្លាប់មនុស្សណាៗក៏បានទាំងអស់ សូម្បីតែខ្លួនឯង ។

គ្រោះកាចអ្វីស្មើនឹងទោសៈមិនមាន ។

កំហុសអ្វីស្មើនឹងទោសៈមិនមាន ។

សេចក្តីក្រោធមានទោស បង្កផលអាក្រក់ឱ្យមកសន្ទឹកសន្ធាប់ ដូចជាព្រះពុទ្ធវចនៈដែលបានសម្តែងមកនេះ បញ្ជាក់ឱ្យដឹងស្រាប់ហើយ ។ សូម្បីរឿងរ៉ាវនៅក្នុងនិទានផ្សេងៗ និងក្នុងជីវិតបច្ចុប្បន្នពិតៗក៏មានសន្ទឹកសន្ធាប់ដែរ សុទ្ធតែសម្តែងឱ្យឃើញថា ការខឹងក្រោធមានតែធ្វើឱ្យកើតសេចក្តីវិនាសខូចខាត មិនមានផលអ្វីល្អទេ ទើបគួរកម្ចាត់បង់ចោល មិនត្រូវទុកឱ្យឋិតនៅឡើយ។ សម្លាប់អ្វីដទៃអាចមកដេកជាទុក្ខ តែសម្លាប់សេចក្តីក្រោធហើយ រមែងដេកជាសុខជារៀងរហូត ។

**នត្ថិ ខន្ធសមា ទុក្ខា**

សេចក្តីទុក្ខទាំងពួងស្មើដោយខន្ធមិនមានឡើយ ។

**នត្ថិ សន្តិបរំ សុខំ**

សុខដទៃក្រៅពីសេចក្តីស្ងប់មិនមានឡើយ ។

-៨-

# ៣-ពិចារណា
# ដល់សេចក្ដីល្អរបស់គេ

ជាធម្មតាមនុស្សយើងដោយទូទៅ ម្នាក់ៗ រមែងមានចំណុចល្អខ្លះ មានចំណុចអាក្រក់ខ្លះ នឹងរកមនុស្សល្អសុទ្ធ មិនឱ្យមានចំណុចខ្វះខាតសោះនោះមិនបានឡើយ។

មានចំណុចខ្លះ យើងថាល្អ អ្នកដទៃថាមិនល្អ ចំណុចខ្លះទៀត យើងថាមិនល្អ តែអ្នកដទៃគេថាល្អ ។ រឿងរ៉ាវ លក្ខណៈ ឬការធ្វើរបស់អ្នកដទៃ ដែលធ្វើឱ្យយើងក្រោធនោះ គឺជាចំណុចខ្សោយ ឬចំណុចខ្វះខាតរបស់គេម្យ៉ាង ឬអាចជាផ្នែកដែលមិនត្រូវចិត្តយើង ។ កាលបើចំណុចមិនល្អរបស់គេ ឬផ្នែកណាមួយរបស់គេដែលមិនត្រូវចិត្តយើងនោះ ធ្វើឱ្យយើងក្រោធខឹង យើងកុំចេះតែនឹកដល់ចំណុចនោះ ផ្នែកនោះរបស់គេតែប៉ុណ្ណោះ គប្បី

បែរទៅមើលឬរលឹកដល់សេចក្ដីល្អរបស់គេផង សេចក្ដីល្អមានដោយកាយ មានដោយវាចា និងមានដោយចិត្ត ។

ម្យ៉ាងទៀត ដែលថាគេជាមនុស្សមិនល្អ ហើយធ្វើឱ្យយើងក្រោធនោះ គឺដោយសារតែលោភៈទោសៈមោហៈក្នុងខ្លួនរបស់គេហ្នឹងឯង ទើបធ្វើឱ្យគេទៅជាមនុស្សមិនល្អយ៉ាងនេះមួយ យ៉ាងនោះមួយ ។ ក្នុងមនុស្សម្នាក់ៗទោះជាអាក្រក់សាមាន្យ ឬសាហាវយង់ឃ្នងយ៉ាងណាក៏ដោយ បើដកយកលោភៈ ទោសៈ និងមោហៈចេញអស់ហើយ ក៏គឺជាព្រះអរហន្តដែលគួរឱ្យយើងថ្វាយបង្គំគោរពបូជាពិតៗ ដូច្នេះ យើងត្រូវរៀនពិចារណា ឱ្យឃើញលោភៈថាជាលោភៈ ឃើញទោសៈថាជាទោសៈ ឃើញមោហៈថាជាមោហៈ តាមសភាវៈពិត គឺត្រូវឱ្យឃើញច្បាស់ថាវាជាកិលេសមារនៅជ្រែកក្នុងមនុស្សគ្រប់គ្នា ។ ការពិចារណាឃើញយ៉ាងនេះ នាំឱ្យយើងកាត់បន្ថយនូវការប្រកាន់ទោសរបស់មនុស្សផងគ្នា ហើយបន្ថែមការចម្រើនករុណាធម៌ទៅលើសត្វលោកទាំងអស់វិញ ព្រមទាំងខ្លួនយើងផង

ព្រោះថា សត្វលោកទាំងអស់ព្រមទាំងខ្លួនយើង សុទ្ធតែជាអ្នកត្រូវកិលេសមារបៀតបៀន ។

## ៤_ពិចារណាថា
## ជាការដាក់ទោសខ្លួនឯងឱ្យសមចិត្តសត្រូវ

≈≈≈≈≈≈≈≈≈≈≈≈≈

ធម្មតាសត្រូវរមែងប្រាថ្នាអាក្រក់ ចង់ឱ្យកើតនូវសេចក្ដីវិនាសហិនហោចដល់គ្នានឹងគ្នា ។

មនុស្សក្រោធនឹងសាងនូវសេចក្ដីវិនាសឱ្យដល់ខ្លួនឯងច្រើនយ៉ាង ដោយសត្រូវមិនចាំបាច់ធ្វើអ្វីឱ្យលំបាកផងក៏បានសមចិត្តរបស់គេ ដូចជា សត្រូវប្រាថ្នាថា សូមឱ្យវាមិនល្អមិនស្អាត មានពណ៌សម្បុរអាក្រក់ ឬសូមឱ្យវាដេកជាទុក្ខ សូមឱ្យវាវិនាសហិនហោចនូវប្រយោជន៍ សូមឱ្យវាវិនាសនូវទ្រព្យសម្បត្តិ វិនាសយស វិនាសចាកមិត្ត និងសូមឱ្យវាស្លាប់ទៅធ្លាក់នរកជាដើម ។ ជាទីសង្ឃឹមបានដូចចិត្តរបស់សត្រូវ ត្រង់ដែលបុគ្គលអ្នកក្រោធហើយ បានធ្វើនូវសេចក្ដីវិនាសទាំងនេះឱ្យកើតមានដល់ខ្លួន សមតាមបំណងដែលសត្រូវរបស់គេប្រាថ្នាហើយ ។

ដោយហេតុនេះ សត្រូវដែលពូកែ ទើបរកវិធីក្លែងញុះញង់ ឱ្យផ្នែកម្ខាងទៀតមានការខឹងក្រោធដោយប្រការផ្សេងៗ ឬក៏ឱ្យមានការបែកបាក់គ្នា ។ កាលបើបានដឹងដូចនេះហើយ គឺមិនត្រូវប្រទូសរ៉ាយខ្លួនឯងដោយការខឹងក្រោធឡើយ ។

វាជាការត្រឡប់បកទៅវិញ កាលបើអាចគ្រប់គ្រងចិត្តបាន គឺប៉ះនឹងអារម្មណ៍ដែលនាំឱ្យក្រោធក៏មិនក្រោធ មិនមានចិត្តញាប់ញ័រ សម្បុរមុខផ្លូវផង់ អាកប្បកិរិយាមិនខុសប្រក្រតី ធ្វើការងារអ្វីៗរបស់ខ្លួនទៅតាមធម្មតា យ៉ាងនេះ រមែងធ្វើឱ្យអ្នកដែលប្រាថ្នាមិនល្អមកលើនោះ បែរទៅជាមានសេចក្ដីទុក្ខទោមនស្សដោយខ្លួនឯងទៅវិញ ឯអ្នកដែលមិនក្រោធក៏ត្រូវបានសម្រេចនូវប្រយោជន៍ មិនមានអ្វីត្រូវវិនាសហិនហោចនោះទេ ។

ការមិនក្រោធមានតែការចម្រើន ធ្វើឱ្យសម្បូណ៌មិត្តខ្សត់សត្រូវ និងទទួលបាននូវជ័យជម្នះក្នុងជីវិត ដែលជាជ័យជម្នះមិនត្រឡប់ចាញ់វិញឡើយ ។



## ៥-ពិចារណាថា
## យើងក្រោធគឺសាងទុក្ខឱ្យខ្លួនឯង

គប្បីពិចារណាក្នុង ៧ចំណុចនេះ :

១-**ប្រហារផ្លូវចិត្តខ្លួនឯងព្រោះសេចក្តីក្រោធ** បើយើងត្រូវចោរបៀតបៀន ក៏ចំពោះតែផ្លូវកាយប៉ុណ្ណោះ ឯចំណែកខ្លួនឯងវិញ ព្រោះការខឹងក្រោធកើតឡើង បានប្រហារ បានបៀតបៀន បានដុតរោលដល់សន្តានចិត្តរបស់ខ្លួនឯង ព្រោះហេតុនេះ បើយើងគិតថា មេត្តាគេមិនបានទេ គឺសូមកុំភ្លេចមេត្តាខ្លួនឯងឱ្យសោះ កុំដុតចិត្តខ្លួនឯងដោយសេចក្តីក្រោធឡើយ ។

២-**គាំទ្រសេចក្តីក្រោធ ដែលកាត់ឫសគល់នៃកុសលទាំងឡាយរបស់ខ្លួន** សេចក្តីក្រោធធ្វើឱ្យយើងវិនាសនូវកុសលគ្រប់យ៉ាង មានកុសលសីលជាដើម កាលបើយើងគាំទ្រសេចក្តីក្រោធ តើយើងហ្នឹងល្ងង់ប៉ុនណាទៅ ?



៣-**ធ្វើអំពើព្រៃផ្សៃឱ្យដល់ខ្លួនឯង ព្រោះសេចក្តីក្រោធ** យើងកើតទុក្ខមិនសុខចិត្ត ដោយគិតថា គេបានធ្វើអំពើព្រៃផ្សៃរំលោភបំពានមកលើយើង ចុះចំណែកខ្លួនយើងដែលដុតចិត្តខ្លួនឯង ឱ្យក្តៅរោលរាល និងដុតបំផ្លាញនូវគុណធម៌ផ្សេងៗទៀតជាច្រើនរបស់ខ្លួននោះ តើវាព្រៃផ្សៃប៉ុនណាដែរទៅ ?

៤-**វាជាចំណុចខ្សោយរបស់យើង** កាលបើអ្នកដទៃចង់បៀតបៀនយើង គេប្រើនូវល្បិចកលផ្សេងៗដើម្បីឱ្យយើងខឹងក្រោធ ដូច្នេះការខឹងក្រោធវាជាចំណុចខ្សោយមួយរបស់យើង ដែលធ្វើឱ្យបំណងរបស់គេបានសម្រេច ។

៥-**គួរឱ្យតិះដៀលខ្លួនឯងណាស់** នៅពេលដែលយើងខឹង ទោះជាយើងប្រាថ្នាបៀតបៀនគេក្តី ឬមិនប្រាថ្នាក្តី តែ

វាបានបៀតបៀនខ្លួនឯងរួចស្រេចទៅហើយ។ តាមធម្មតា យើងស្រឡាញ់ខ្លួនឯងខ្លាំងណាស់ តែដល់ពេលខឹងក្រោធ យើងល្ងង់ដល់ថ្នាក់បៀតបៀនខ្លួនឯង ។

**៦.ឡើងកាន់ផ្លូវទៅរកគ្រោះថ្នាក់** បើយើងដឹងថាពួកអ្នកក្រោធទាំងឡាយ ឡើងកាន់ផ្លូវគ្រោះថ្នាក់ ផ្លូវមរណៈទៅហើយនោះ ហេតុអ្វីយើងត្រូវទៅតាមផ្លូវនោះដែរ ឬមួយយើងមិនដឹងថា សេចក្ដីក្រោធជាផ្លូវនៃសេចក្ដីវិនាសអន្តរាយទេ ?

**៧.ខន្ធ ៥ ជាទុក្ខ ឬព្រោះយើងកើតមកទើបយើងមានទុក្ខ** មានសត្រូវណាមកធ្វើទុក្ខឱ្យយើងបាន បើយើងមិនកើតមកទេនោះ អធិប្បាយថា ព្រោះបញ្ចក្ខន្ធកើតឡើងទើបមានទុក្ខ ទុក្ខរមែងមិនមាន កាលណាដែលអស់បញ្ចក្ខន្ធ ។

**អក្កោធេន ជិនេ កោធំ**

ឈ្នះសេចក្ដីក្រោធបានដោយការមិនក្រោធ ។

-១៥-

## ៦.ពិចារណាថា
## សត្វមានកម្មជារបស់ខ្លួន

គប្បីពិចារណាថា ទាំងយើងទាំងគេ សុទ្ធតែមានកម្មជារបស់ខ្លួន រៀងៗខ្លួន ធ្វើកម្មអ្វីទុកមកក៏បានទទួលផលនៃកម្មនោះ ។ ផ្ដើមដោយការពិចារណាខ្លួនឯងថា បើយើងក្រោធហើយ ទោះជាធ្វើអ្វីក៏ដោយ ការធ្វើរបស់យើងនោះកើតពីទោសៈដែលជាអកុសលមូល កម្មរបស់យើងក៏រមែងជាកម្មអាក្រក់ ដែលនឹងបង្កឱ្យកើតផលអាក្រក់ មានតែសេចក្ដីក្ដៅក្រហាយ មិនជាប្រយោជន៍ក្នុង

លោកនេះ ហើយយើងនឹងទទួលផលរបស់កម្មនោះតទៅមុខវែងឆ្ងាយទៀត ។

ម្យ៉ាងទៀត កាលបើយើងធ្វើកម្មអាក្រក់ដែលកើតអំពីទោសៈនោះ មុននឹងយើងបៀតបៀនបំផ្លាញអ្នកដទៃយើងបានប្រទូសរ៉ាយជាមួយនឹងខ្លួនឯង ដុតរោលខ្លួនឯងជាមុនស្រេចទៅហើយ ដូ១៦យកដៃទាំងពីរចាប់ដុំរងើកភ្លើង គប់គ្រវែងដាក់អ្នកដទៃ វារមែងឆេះដៃខ្លួនឯងជាមុន ឬដូចយកដៃចាប់លាមកចោលដាក់ទៅគេ ក៏ធ្វើឱ្យខ្លួនឯងស្អុយជាមុនរួចស្រេចទៅហើយដែរ ។

កាលពិចារណាអំពីកម្មដែលខ្លួនឯងបានធ្វើ ដូច្នេះហើយ គប្បីពិចារណា ទៅលើអ្នកដទៃក្នុងទំនងដូចគ្នា គឺកាលដែលគេក្រោធហើយ គេបានធ្វើនូវកម្មអាក្រក់ គេនឹងទទួលផលកម្មរបស់គេតទៅ កម្មអាក្រក់នោះ នឹងមិនជួយឱ្យគេបានទទួលផលល្អ មានសេចក្ដីសុខអ្វីឡើយ មានតែផលអាក្រក់ ចាប់ផ្ដើមតាំងអំពីដុតរោលចិត្តរបស់គេជាដើមទៅ ។

ក្នុងកាលដែលមនុស្សយើងមានកម្មជារបស់ខ្លួនរៀងៗខ្លួន ទទួលផលកម្មរៀងៗខ្លួន ដូច្នេះ យើងមិនចាំ-បាច់គិតខ្វល់ខ្វាយឱ្យក្ដៅក្រហាយចិត្តនោះទេ តាំងចិត្តធ្វើតែអំពើល្អទៅបានហើយ ។

-១៧-

## ៧-ពិចារណា
## បុព្វចរិយារបស់ព្រះពុទ្ធជាអង្គម្ចាស់

ព្រះពុទ្ធជាអង្គម្ចាស់មុននឹងបានត្រាស់ដឹង ទ្រង់បានបំពេញនូវព្រះបារមីទាំងឡាយ អស់កាលដ៏យូរអង្វែងរហូតមក ទ្រង់បានបំពេញនូវប្រយោជន៍ឱ្យដល់អ្នកដទៃ ដោយព្រះអង្គព្រមលះបង់សូម្បីតែព្រះជន្មរបស់ព្រះអង្គឯង ។

ព្រះអង្គកាលដែលត្រូវគេបៀតបៀន ដោយវិធីផ្សេងៗ ទ្រង់មិនក្រោធឡើយ ទ្រង់យកសេចក្ដីល្អចូលមក

ជំនួស ។ ដល់ទៅថ្នាក់គេតាំងខ្លួនជាសត្រូវនឹងព្រះអង្គ ព្យាយាមសម្លាប់ព្រះអង្គ ទ្រង់ក៏មិនមានចិត្តគិតប្រទូសរ៉ាយដែរ ។ ពេលខ្លះព្រះអង្គជួយគេដោយប្រឹងប្រែងជាទីបំផុត ជំនួសអ្វីដែលគេត្រូវដឹងគុណ គេត្រឡប់បែរជាប្រទូសរ៉ាយមករកព្រះអង្គវិញ ទោះបីយ៉ាងនេះក៏ដោយ ក៏ព្រះអង្គមិនក្រោធដែរ ព្រះអង្គនៅតែធ្វើល្អដល់គេតទៅទៀត ។

ពុទ្ធចរិយាដូចដែលពោលមកនេះ ជាគុណជាតិដែលមនុស្សទូទៅលំបាកនឹងបដិបត្តិបាន តែក៏ជាតួយ៉ាងដ៏ល្អ ដែលពុទ្ធបរិស័ទគួរនាំយកមករំលឹកដាស់តឿនខ្លួន ក្នុងកាលដែលបានជួបប្រសព្វនូវហេតុការណ៍ផ្សេងៗ ។ ការនាំយកនូវពុទ្ធចរិយាជាតួយ៉ាងបែបនេះមករំលឹកដាស់តឿនខ្លួន នាំឱ្យយើងមានសេចក្តីអត់ធន់ ព្រោះអ្វីដែលយើងបានទទួលដូចសព្វថ្ងៃនេះ កាលបើប្រៀបធៀបជាមួយនឹងព្រះ-ពុទ្ធជាអង្គម្ចាស់ ដែលទ្រង់ធ្លាប់បានជួបប្រសព្វមកហើយនោះ រឿងរបស់យើងចាត់ថាបន្តិចបន្តួចណាស់ គឺមិនអាចប្រៀបធៀបនឹងព្រះអង្គបានទេ ។

ក្នុងហេតុការណ៍ដែលព្រះពុទ្ធជាអង្គម្ចាស់ ទ្រង់បានជួបប្រសព្វមកហើយនោះ គឺធ្ងន់ធ្ងរក្រៃលែងណាស់ ព្រះអង្គនៅតែរម្ងាប់សេចក្តីក្រោធបាន នៅតែមានមេត្តាតទៅទៀត ចុះវាជាអ្វីដែរ ចំពោះករណីបន្តិចបន្តួចរបស់យើងនេះ ដែលយើងជាសិស្សរបស់ព្រះអង្គថាមិនអាចរម្ងាប់បាន ។ បើយើងមិនដើរតាមព្រះចរិយាវត្តរបស់

-១៩-

ព្រះអង្គទេ គឺជាការមិនសមគួរឡើយ ត្រង់ដែលយើងយកព្រះអង្គជាព្រះសាស្តានោះ ។

ពុទ្ធចរិយាវត្ត ទាក់ទងនឹងសេចក្តីអត់ធន់ ការលះ-បង់ ព្រមទាំងមេត្តាករុណារបស់ព្រះអង្គ លោកបានចងក្រងទុកក្នុងព្រះជាតក មានច្រើនរឿងណាស់ ហើយដោយច្រើនសុទ្ធតែវែងៗ ដែលមិនអាចនាំយកមកសម្តែងទុកក្នុងទីនេះបាន គ្រាន់តែសូមលើកយកព្រះជាតក ជាតួយ៉ាងខ្លីៗ និងដោយសេចក្តីសង្ខេបមកតែប៉ុណ្ណោះ :

គ្រាមួយ ព្រះបរមពោធិសត្វកើតជាព្រះរាជាក្រុងពារាណសី មានព្រះនាមថា **ព្រះបាទមហាសីលវៈ** គ្រា

នោះអាមាត្យម្នាក់របស់ព្រះអង្គមានកំហុស ត្រូវនិរទេស។ អាមាត្យនោះឯងបានចូលទៅបម្រើការថ្វាយព្រះបាទកោ-សល ។ ដោយអាមាត្យនោះមានគំនុំក៏បានឱ្យចោរចូលមកលួចប្លន់ នៅក្នុងដែនដីរបស់ព្រះបាទមហាសីលវៈជារឿយៗ ។ កាលដែលរាជបុរសចាប់ចោរទាំងនោះបាន ព្រះមហាសីលវៈទ្រង់ទូន្មានអប់រំហើយ ក៏លែងឱ្យរួចខ្លួនទៅ ព្រមទាំងបានប្រទានទ្រព្យឱ្យខ្លះផង ដូចនេះជានិច្ច ។

ក្នុងទីបំផុត អាមាត្យកំហូចនោះ ក៏យកហេតុ-ការណ៍ទាំងអស់នេះ មកញុះញង់ព្រះបាទកោសលថា ព្រះបាទសីលវៈទន់ខ្សោយណាស់ បើលើកទ័ពទៅច្បាំងគង់នឹងដណ្តើមយកនគរពារាណសីបានដោយងាយ ។ ព្រះបាទកោសលទ្រង់ជឿ ទើបលើកកងទ័ពចូលមកច្បាំងដណ្តើមយកនគរពារាណសី ។ ព្រះមហាសីលវៈទ្រង់មិនឱ្យប្រជារាស្ត្រក្តៅក្រហាយដោយសង្គ្រាម ទើបព្រះអង្គមិនតប ត អ្វីឡើយ ព្រះអង្គបណ្តោយឱ្យព្រះបាទកោសលដណ្តើមយករាជសម្បត្តិហើយចាប់ព្រះអង្គបាន ។ ព្រះបាទកោសលចាប់ព្រះបាទសីលវៈបានហើយ ក៏ឱ្យយកទៅកប់ទាំងរស់ត្រឹមក ក្នុងព្រៃស្មសាន រង់ចាំដល់ពេលយប់ជ្រៅនឹងឱ្យឆ្កែចចកមកស៊ីតាមវិធីប្រហារជីវិតក្នុងសម័យនោះ។

ដល់ពេលពាក់កណ្តាលយប់ ឆ្កែចចកចូលមក ព្រះ-បាទសីលវៈទ្រង់ប្រើប្រាជ្ញានិងសេចក្តីក្លាហាន បានយកចង្កាសង្កត់មាត់ឆ្កែចចកមួយ ដែលចូលមករកខាំករបស់ព្រះអង្គ កាលឆ្កែនោះភ្ញាក់ផ្អើលនិងខំប្រឹងរើបម្រះរើរក់នោះ ឆ្កែចចកផ្សេងៗទៀតក៏រត់ទៅ ហើយធ្វើឱ្យដីក្នុងបរិវេណរណ្តៅកប់ព្រះអង្គ ខ្ទាត់ខ្ទាយរបើកចេញ រហូតដល់ធ្វើឱ្យទ្រង់កែខៃនាំខ្លួនព្រះអង្គចេញមកបាន ។

នៅក្នុងពេលយប់នោះឯង ទ្រង់បានលបចូលទៅរហូតដល់បន្ទប់ផ្ទំរបស់ព្រះបាទកោសល ព្រមដោយព្រះ-ខ័ន ទ្រង់ទុកជីវិតព្រះបាទកោសល ទ្រង់ព្រះរាជទានអភ័យ ហើយទ្រង់យកព្រះនគររបស់ព្រះអង្គមកវិញ ។ ព្រះបាទកោសលស្បថមិនឈ្លានពាននគរពារាណសីទៀតឡើយ ។

ព្រះបាទសីលវមហារាជ ទ្រង់បានស្ដាបនាព្រះបាទកោសលឱ្យជាសម្លាញ់ ហើយទ្រង់ឱ្យត្រឡប់ទៅគ្រប់គ្រងដែនកោសលដូចដើមវិញ តរៀងទៅ ។

អាមាត្យកំហូចបានមកជាទេវទត្ត ។ ឯចំណែក **ព្រះបាទសីលវមហារាជបានមកជាព្រះតថាគត។**

(មហាសីលវជាតក ក្នុងឯកនិបាតជាតក ចប់ដោយសង្ខេប)

រឿងមួយទៀត គឺព្រះបរមពោធិសត្វ កើតជាមហា

-២២-

ពានរនៅក្នុងព្រៃ ។ គ្រានោះមានបុរសម្នាក់តាមរកគោរបស់ខ្លួន បានចូលមកកណ្ដាលព្រៃ ហើយភ្លាត់ជើងធ្លាក់ចូលទៅក្នុងជ្រោះ ឡើងមិនរួច អត់អាហារ អស់កម្លាំងស្លេកស្លាំងនៅក្នុងជ្រោះហ្នឹងឯង ។

១០ ថ្ងៃកន្លងមក មហាពានរក៏បានចុះទៅជួបកើតក្ដីអាណិត ទើបជួយឱ្យឡើងមកបាន ។ កាលមហាពានរហត់នឿយទើបសម្រាកយកកម្លាំង ហើយក៏ដេកលក់ទៅ ។ បុរសនោះបានកើតគំនិតអាក្រក់ ដោយគិតថា ស្វានេះ ក៏ជាអាហាររបស់មនុស្ស ដូចសត្វព្រៃដទៃៗទៀតដែរ ឥឡូវនេះអញឃ្លានខ្លាំងណាស់ អញនឹងសម្លាប់ស្វានេះស៊ីរួចហើយនៅសល់សាច់ អញនឹងយកទុកធ្វើជាស្បៀង ទៅតាមផ្លូវ ។ គិតដូច្នេះហើយ ក៏បានរកដុំថ្មធំមួយដុំ យកមកគប់ក្បាលមហាពានរក្នុងពេលនោះឯង ។ ដុំថ្មនោះបានធ្វើឱ្យមហាពានររបួសជាទម្ងន់ តែមិនដល់ស្លាប់ទេ ដោយសារកម្លាំងគប់នោះមានសភាពខ្សោយ ។

មហាពានរភ្ញាក់ដឹងខ្លួន ប្រឹងគេចរត់ឡើងទៅលើដើមឈើ សម្លឹងមើលមកមនុស្សអាក្រក់ដែលជាមនុស្សទ្រុស្ដមិត្តនោះទាំងឈាមកំពុងហូរស្រោចខ្លួន ។ ដោយក្រែងថាបុរសនោះវង្វេងរកផ្លូវចេញពីព្រៃមិនបាន ដូច្នេះទាំងដែលខ្លួនឯងកំពុងតែឈឺចាប់ដ៏ខ្លាំងក្លា ក៏នៅខំលោតទៅតាមមែកឈើ ដើម្បីជួយនាំផ្លូវឱ្យបុរសនោះចេញផុតពីព្រៃទៀតផង ។

(មហាកបិជាតកក្នុងតឹសតិនិបាតចប់ដោយសង្ខេប)

**ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ**
**អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ។**

ក្នុងកាលណាក៏ដោយ ធម្មតាពៀរទាំងឡាយក្នុងលោកនេះ មិនដែលស្ងប់រម្ងាប់ ដោយការចងពៀរ

## -២៤-
## ៨-ពិចារណា
## ញាតិក្នុងសង្សារវដ្ដ

មានព្រះពុទ្ធវចនៈកន្លែងមួយបានសម្ដែងថា ក្នុងសង្សារវដ្ដ គឺការវិលវល់កើតស្លាប់ដែលកំណត់ទីបំផុតខាងដើមមិនបាននេះ សត្វណាដែលមិនធ្លាប់ជាមាតា មិនធ្លាប់ជាបិតា មិនធ្លាប់ជាបុត្រ មិនធ្លាប់ជាធីតានឹងគ្នា សត្វនោះមិនងាយរកបានទេ ដូច្នេះ កាលបើមានហេតុនាំឱ្យក្រោធកើតឡើងពីអ្នកណា គប្បីពិចារណាថា បុគ្គលនោះធ្លាប់ជាមាតារបស់យើង បុគ្គលនោះធ្លាប់ជាបិតារបស់យើង ។

អ្នកដែលជាមាតានោះ រក្សាកូនទុកក្នុងពោះជាច្រើនខែ គ្រាកាលកើតចាកផ្ទៃមកហើយ ក៏ចិញ្ចឹមថែរក្សា មិនខ្ពើមមូត្រលាមក ទឹកមាត់ទឹកសម្បោរជាដើម ចាប់កាន់ជូតលាងដោយដៃយ៉ាងស្និទ្ធ ឱបកូន ពកូន បីកូន បំបៅដោះ ចិញ្ចឹមកូនឱ្យរស់ ឱ្យរៀន ។ល។

-២៥-

ចំណែកលោកជាបិតា ត្រូវដើរផ្លូវលំបាក ផ្លូវឆ្ងាយ ជួបភ័យព្រួយក្នុងមុខរបរជួញដូរ បិតាខ្លះទៅធ្វើសង្គ្រាម បិតាខ្លះចុះទូកទៅកណ្ដាលសមុទ្រ បិតាខ្លះធ្វើការលំបាកផ្សេងៗទៀត ដើម្បីប្រមូលទ្រព្យមក ដោយគិតថានឹងចិញ្ចឹមកូនតូច ។

ទោះជាមិនមែនមាតាបិតា ក៏អាចជាបង ជាប្អូន ជាញាតិ ជាមិត្ត ដែលធ្លាប់បានរួមសុខទុក្ខជាមួយគ្នា ។

ដូច្នេះ ការដែលមានចិត្តអាក្រក់ ខឹងក្រោធស្អប់ខ្ពើមដល់បុគ្គលទាំងនោះគឺជាការមិនសមគួរសោះឡើយ។

ព្រោះតែការហួងហែងកូនប្រុសស្រី សន្សំទ្រព្យទុកសម្រាប់កូន ទើបបានមិនធ្វើទាន មិនបានរក្សាសីល ភ្លាត់គតិខ្លួនឯងទៅនរក ឬប្រេតតិរច្ឆាន អស់កាលដ៏យូរអង្វែង ទើបបានកើតមកជាមនុស្សកំសត់ក្រីក្រ ពិការខ្វាក់ខ្វិន លំបាកលំបិន ត្រាច់ចរសូមទាន ដូច្នេះ ទើបយើងមិនត្រូវញ៉ាំងចិត្តឱ្យប្រទូស្ត ឬ ឱ្យស្អប់ខ្ពើមទៅលើអ្នកដែលធ្លាប់ពលីជីវិតចំពោះយើងឡើយ ។

-២៦-

## ៩_ពិចារណា

## អានិសង្សរបស់មេត្តា

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈

ធម៌ដែលផ្ទុយគ្នាពីសេចក្តីក្រោធ គឺមេត្តា។ សេចក្តីក្រោធមានទោស បង្កផលអាក្រក់ដ៏ក្រៃលែង យ៉ាងណា មេត្តាក៏មានគុណ បង្កផលល្អច្រើនក្រៃលែងដូច្នោះដែរ ។ កាលបើដូចនេះ ទើបគួររម្ងាប់សេចក្តីក្រោធ ហើយតាំងចិត្តមេត្តាមកជំនួសវិញ ឱ្យមេត្តាហ្នឹងឯង ជួយកម្ចាត់កម្ចាយ និងការពាររារាំងសេចក្តីក្រោធ រហូតដល់បានឈ្នះជាស្ថាពរ ។

អ្នកមានមេត្តាអាចយកឈ្នះចិត្តអ្នកដទៃបាន ជាជ័យជម្នះដ៏ប្រសើរ អ្នកដែលតាំងនៅក្នុងមេត្តា ឈ្មោះថាធ្វើនូវប្រយោជន៍ទាំងពីរ គឺប្រយោជន៍ខ្លួនឯង និងប្រយោជន៍អ្នកដទៃ ។

មេត្តាបានធ្វើចិត្តឱ្យស្រស់ថ្លា ស្អាតផូរផង់ មានសេចក្តីសុខ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងអានិសង្សរបស់មេត្តាមាន ១១ ប្រការ :

-២៧-

**១-ដេកលក់ជាសុខ** បើយើងក្រោធជាមួយអ្នកដទៃ យើងបីដូចជាត្រូវថ្នាំពិស មិនបានដេកនៅជាសុខឡើយ ដូច្នេះ ទើបត្រូវចម្រើននូវមេត្តា រស់នៅជាមួយនឹងមេត្តាធម៌ ព្រមទាំងគុណធម៌ផ្សេងៗទៀតផង ។

**២-ភ្ញាក់ឡើងក៏ជាសុខ** សុខសប្បាយក្នុងចិត្តដោយពីថ្ងៃមុនមិនបានធ្វើអាក្រក់ព្រោះក្រោធឡើយ និងដោយនឹកឃើញដល់អំពើល្អដែលខ្លួនបានធ្វើហើយ ។

**៣-មិនយល់សប្តិអាក្រក់** សូម្បីតែយល់សប្តិក៏ឃើញតែអារម្មណ៍ល្អៗ ដូចជា ថ្វាយបង្គំព្រះពោធិព្រឹក្ស ហែកឋិន និងឃើញធ្វើបុណ្យផ្សេងៗទៀត ដោយមិនបានយល់សប្តិឃើញកាប់ចាក់ឈ្លោះប្រកែកគ្នាជាដើមឡើយ ។

**៤-ជាទីស្រឡាញ់នៃមនុស្សទាំងឡាយ** បើយើងត្រូវការឱ្យមនុស្សទាំងឡាយស្រឡាញ់យើង គឺយើងត្រូវរៀនឱ្យចេះស្រឡាញ់អ្នកដទៃជាមុនសិន គឺរៀនឱ្យមានមេត្តា។

**៥-ជាទីស្រឡាញ់នៃអមនុស្សទាំងឡាយ** យើងត្រូវទុកអមនុស្សទាំងឡាយ ទេវតាទាំងឡាយជាមិត្តរួមកើត រួមចាស់ រួមឈឺ រួមស្លាប់ជាមួយនឹងយើង ។ នៅពេលដែលយើងធ្វើកុសលអ្វីមួយរួចហើយ យើងត្រូវឧទ្ទិសកុសលនោះឱ្យដល់អមនុស្សនិងទេវតាទាំងឡាយផង ។

**៦-ទេវតាទាំងឡាយជួយថែរក្សា** ទោះជាទេវតារក្សាក៏មិនអាចរក្សាចិត្តយើងបានដែរ គឺមានតែគុណធម៌ មានមេត្តាជាដើមប៉ុណ្ណោះទេ ដែលអាចរក្សាចិត្តយើងបាន ។

**៧-មិនត្រូវគ្រោះថ្នាក់ដោយសស្ត្រាវុធជាដើម ដែលជាអន្តរាយខាងក្រៅឡើយ** មេត្តាជាធម៌រម្ងាប់នូវពៀរ អ្នកចម្រើននូវមេត្តាជាអ្នកស្លូតបូត រហូតដល់បានសម្រេចអប្បនាសមាធិជាគុណជាតិដ៏ប្រសើរ ដែលអាចការពារអន្តរាយបាន ។

**៨-មានចិត្តតាំងមាំបានដោយឆាប់** មេត្តាធម៌ ជាធម៌មានឧបការៈដល់កុសលធម៌ដទៃទៀតខ្លាំងក្លាណាស់ ទោះជាទានក្តី សីលក្តី សមថភាវនាក្តី វិបស្សនាភាវនាក្តី ។

**៩-សម្បុរមុខស្រស់ថ្លា** ព្រោះដោយអំណាចនៃមេត្តាបានញុំាងឱ្យរូបស្រស់បស់ មុខគួរឱ្យរាប់អាន ។ ទោះបីអ្នកស្អាតពីកំណើតមកក៏ដោយ ក៏ព្រោះមកអំពីមានបុណ្យដែលបានធ្វើហើយនោះប្រកបដោយមេត្តាដែរ ។

**១០-មិនវង្វេងនៅពេលជិតស្លាប់** មនុស្សដែលវង្វេងនៅពេលជិតស្លាប់ ព្រោះបាត់បង់ស្មារតី ឯធម៌មេត្តាជាគុណជាតិញុំាងស្មារតីឱ្យចម្រើន មិនសន្សំការខឹងក្រោធដែលជាបាបនាំឱ្យវង្វេងនោះឡើយ ។

**១១-កាលបើមិនទាន់ត្រាស់ដឹងនូវគុណធម៌ជាន់ខ្ពស់ គឺព្រះអរហត្តទេ រមែងចូលទៅកាន់ព្រហ្មលោកដោយអំណាចនៃមេត្តាចេតោវិមុត្តិ ។**

បើជាអ្នកនៅច្រើនទៅដោយសេចក្តីក្រោធ ឈ្មោះថា ជាអ្នកនៅឆ្ងាយអំពីការបានអានិសង្សទាំងនេះ ដូច្នេះទើបគួរព្យាយាមចម្រើនមេត្តា ឱ្យជាធម៌ប្រចាំចិត្ត ប្រចាំជីវិត ហ្វឹកហាត់អប់រំឱ្យមានមេត្តាជាប្រក្រតីរៀងរាល់ថ្ងៃ ព្រោះថា បើមេត្តាចិត្តនៅមិនទាន់បានមាំទាំទេ គឺមិនអាចយកឈ្នះសេចក្តីក្រោធបានឡើយ ។



## ១០-ពិចារណា
## ដោយវិធីចែកធាតុ

ការពិចារណាបែបនេះ ជាការបដិបត្តិកៀកជិតនឹងវិបស្សនា ឬយកការចេះដឹងខាងវិបស្សនាវិជ្ជាមកប្រើជាប្រយោជន៍ បានដល់ការសម្លឹងមើលជីវិតនេះ សម្លឹងមើលសត្វបុគ្គល យើង គេ តាមសេចក្តីពិតថា ត្រឹមតែជាគ្រឿងប្រកបផ្សំទាំងឡាយ ។ ដោយធាតុទាំងឡាយផ្សេងៗប្រជុំចូលគ្នាហើយ ក៏សន្មតហៅគ្នាទៅថាមនុស្ស ហៅថាសត្វ ជាយើង ជាគេ ជាបុរស ជាស្ត្រីជាដើមអ៊ីចឹងទៅ ។ បើនឹងចង្អុលបង្ហាញថា ត្រង់ណាជាមនុស្ស ជាសត្វ ជាយើង ជាគេ គឺរកមិនឃើញឡើយ ឃើញមានត្រឹមតែធាតុទាំង-ឡាយដូចជាធាតុរឹងខ្លះ ធាតុរាវខ្លះជាដើម ឬជារូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ តែប៉ុណ្ណោះឯង ឬពុំនោះសោត ក៏ជាអាយតនៈ មានភ្នែក ត្រចៀក ច្រមុះ ជាបសាទរូប និងអាយតនៈខាងក្រៅ ជារូប សម្លេង ក្លិន ជាដើម រួមមកគឺរូបធម៌ខ្លះនាមធម៌ខ្លះ ។

កាលពិចារណាទៅតាមសេចក្តីពិត បានចែកឱ្យជាចំណែកៗដូចនេះហើយ យើងរកអ្នកដែលយើងក្រោធនោះពុំឃើញឡើយ តើយើងក្រោធនឹងអ្វី ? ក្រោធនឹង

សក់ សរសៃ ឆ្អឹង ក្រោធនឹងរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ឬក៏ក្រោធនឹងអ្វីផ្សេងទៀត ?

ទីបំផុតក៏រកទីតាំងនៃសេចក្ដីក្រោធមិនបាន គឺមិនមានអ្វី ដែលសម្រាប់ឱ្យសេចក្ដីក្រោធចាប់តោងឡើយ ។

មនុស្សយើងដែលចេះតែឈ្លោះគ្នា ស្អប់គ្នា គុំគួនគ្នា ព្រោះមិនបានមើលឱ្យឃើញដល់ធាតុពិត១ ក្នុងខ្លួនម្នាក់១ រវល់តែជាប់ជំពាក់ប្រកាន់ថាជាអ្នកនេះ ថាជាអ្នកនោះ ម្ល៉ោះហើយបញ្ហាម៉ឺនសែនជំពូកនៅក្នុងខ្លួនម្នាក់១ ដោះស្រាយមិនចេះអស់ ។

អ្វី១ទាំងអស់សុទ្ធតែជាសភាវៈពិត ជាការពិត ជាសច្ចធម៌ ប៉ុន្តែដោយអំណាចនៃសេចក្ដីល្ងង់គឺអវិជ្ជា ក៏សំគាល់នូវការពិតខ្លះថាជាគ្រឿងនាំឱ្យរីករាយ ឯការពិតខ្លះទៀត ក៏សំគាល់ថាជាបញ្ហា ។ កាលបើសំគាល់ថាជាបញ្ហាហើយ ក៏ខ្វាយខ្វល់ ភ័យព្រួយ ឬក៏ខឹងក្រោធហ្នឹងឯង ។



ទោះជាយ៉ាងណាក៏ដោយ មនុស្សយើងដែលមិនបានអប់រំចម្រើនបញ្ញា មិនអាចពិចារណាចែកធាតុទៅបានទេ ឬគ្រាន់តែចែកទៅតាមការដែលបានស្ដាប់ បានអានមកប៉ុណ្ណោះ ដោយមើលមិនឃើញតាមសេចក្ដីពិតឡើយ ដូច្នេះហើយ ការកែខៃសេចក្ដីក្រោធដែលកើតឡើង រមែងមិនបានសម្រេច បើយ៉ាងនេះ គប្បីមានដំណើរការតាមវិធីជាបន្តទៀត ។

**អសាធុំ សាធុនា ជិនេ**

ឈ្នះនូវសេចក្ដីអាក្រក់បានដោយសេចក្ដីល្អ ។



## ១១-ការពិចារណា

## ហេតុផល និង បដិបត្តិក្នុងការឱ្យទាន

≈≈≈≈≈≈≈≈≈≈≈

សូមឱ្យពុទ្ធបរិស័ទទាំងឡាយ ជាមនុស្សធ្ងន់ក្នុងហេតុផល ព្រោះថាអ្វីៗទាំងអស់ក្នុងលោកយើងនេះ សុទ្ធតែមានហេតុផលទាំងអស់ ។ អំពើអាក្រក់ក៏មានហេតុនៃអំពើអាក្រក់ អំពើល្អក៏មានហេតុនៃអំពើល្អដែរ ។ ធម៌ទាំងឡាយសុទ្ធតែកើតពីហេតុ ប្រព្រឹត្តទៅតាមហេតុ ធម៌ទាំងឡាយមិនគួរប្រកាន់ថាជារបស់មាំមួនឡើយ ។

កាលសេចក្តីក្រោធបាត់បង់ទៅ សេចក្តីស្រឡាញ់ក៏ចូលមកជំនួស ភាពជាសត្រូវក៏ក្លាយជាមិត្ត ភ្លើងព្យាបាទក៏ក្លាយជាទឹកមន្តដ៏ស័ក្តិសិទ្ធគឺមេត្តាធម៌ ការដុតរោលចិត្តឱ្យពុះក្តៅក៏ក្លាយទៅជាការស្រោចស្រពចិត្តឱ្យផូរផង់ ឱ្យស្រស់ថ្លា នៅដោយសេចក្តីសុខស្ងប់ ។

ការឱ្យទានត្រូវបដិបត្តិឱ្យជាប្រចាំ ឱ្យទៅជាទម្លាប់មានឧបនិស្ស័យក្នុងការឱ្យទាន សប្បាយចិត្តនឹងឱ្យ លុះឱ្យរួចហើយរមែងមាននូវសេចក្តីសុខ ។
-៣៥-

ចំពោះវិធីបដិបត្តិកម្ចាត់សេចក្តីក្រោធ ដោយអាស្រ័យការឱ្យទាននេះ គឺត្រូវយកទ្រព្យសម្បត្តិរបស់ខ្លួន ឱ្យដល់មនុស្សដែលយើងខឹងក្រោធ ឬស្អប់នោះ និងទទួលយករបស់ដែលគេនោះឱ្យមកខ្លួនវិញផង ឬយ៉ាងហោចណាស់ត្រូវតែធ្វើជាអ្នកឱ្យកុំខាន ព្រោះការឱ្យទានជាការចងមិត្ត ដូច្នេះ ត្រូវតែឱ្យរឿយៗ ព្រមដោយពាក្យសម្តីពីរោះប្រកបផ្សំទៀតផង ។

ការឱ្យទានគឺជាការធ្វើចម្បាំង គឺច្បាំងនឹងសេចក្តីកំណាញ់ផង ច្បាំងនឹងខ្មាំងគឺសេចក្តីក្រោធក្នុងខ្លួនយើងផង ។ តាមធម្មតា បើមនុស្សណាដែលយើងមិនខឹង មិនស្អប់ទេ យើងអាចឱ្យបាន គ្រាន់តែយើងមិនកំណាញ់ប៉ុណ្ណឹងយើងឱ្យបានហើយ ប៉ុន្តែ ចំពោះមនុស្សដែលយើងខឹងក្រោធ យើងស្អប់វិញនោះ យើងពិតជាលំបាកបដិបត្តិក្នុងវិធីនេះណាស់ ដូច្នេះយើងត្រូវកុំភ្លេចថា« សត្រូវរបស់យើងពិតប្រាកដ គឺសេចក្តីក្រោធ យើងធ្វើសង្គ្រាមជាមួយ
-៣៥-
សេចក្តីក្រោធ ដោយការឱ្យទាន »។

ការឱ្យទាន ជាវិធីកែខៃដោះស្រាយសេចក្តីក្រោធដែលនាំឱ្យសម្រេចផលបានល្អប្រសើរ និង នាំឱ្យយើង

ឈានទៅរកការដោះស្រាយដោយវិធីផ្សេងៗទៀតផង ។ ការឱ្យទានអាចរម្ងាប់នូវការចងពៀរវេរា ដែលមានមកអស់កាលដ៏យូរអង្វែងហើយ ឱ្យស្ងប់ទៅបាន ធ្វើឱ្យសត្រូវក្លាយជាមិត្ត ។ ការឱ្យទាន ជាមេត្តា ករុណាដែលសម្តែងចេញមកខាងក្រៅតាមរយៈនៃកាយកម្ម ឬវចីកម្ម ។

ការឱ្យទានជាគ្រឿងហ្វឹកហាត់មនុស្សដែលមិនទាន់ហ្វឹកហាត់បាន ។ ការឱ្យទានរមែងញ៉ាំងនូវរបស់ដែលប្រាថ្នាទាំងពួងឱ្យបានសម្រេច ។ អ្នកឱ្យទានក៏រីករាយចិត្តនឹងអំពើល្អរបស់ខ្លួន រីឯអ្នកទទួលក៏បាននូវសេចក្តីសុខ ។

ការឱ្យទានគឺជាបារមីទី ១ ដែលនាំឱ្យព្រះបរម-ពោធិសត្វបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ។ បុគ្គលដែលមិនមែនជាបុគ្គលពាល រមែងសរសើរការឱ្យទាន ។



## ១២-ពិចារណា
## តាមសេចក្តីនៃព្រះពុទ្ធភាសិត

-សេចក្តីក្រោធមិនល្អឡើយ ។

-សេចក្តីក្រោធជាស្នឹមនៃបញ្ញា ដូចជាស្នឹមនៃសស្ត្រាវុធ ។

-សេចក្តីក្រោធបង្កការវិនាស ។

-សេចក្តីក្រោធញ៉ាំងចិត្តឱ្យកម្រើក ។

-បុគ្គលអ្នកក្រោធមិនដឹងថាសេចក្តីក្រោធគឺជាភ័យដែលកើតឡើងក្នុងខ្លួនឡើយ ។

-នៅពេលណាសេចក្តីក្រោធគ្របសង្កត់ នៅពេលនោះមានតែភាពងងឹតប៉ុណ្ណោះ ។

-ពីតិចទៅច្រើន សេចក្តីក្រោធចេះតែចម្រើន ព្រោះមកអំពីការមិនអត់ធន់ ។

-សេចក្តីក្រោធជាទីគោចរនៃអ្នកខ្សត់បញ្ញា ។

-ទោសៈមានសេចក្តីក្រោធជាសមុដ្ឋាន ។



-គ្រោះអ្វីក៏មិនស្មើនឹងទោសៈដែរ ។

-ចង្រៃកាឡកិណីអ្វីឱ្យដូចជាទោសៈមិនមាន ។

-សម្លាប់សេចក្តីក្រោធបាន ទើបដេកជាសុខ ។

-សម្លាប់សេចក្តីក្រោធបាន ទើបមិនមានសោក ។

-បុគ្គលក្រោធរមែងមានពណ៌សម្បុរសៅហ្មង ។

-បុគ្គលក្រោធដែលកាន់យកនូវប្រយោជន៍បាន ហើយ បែរទៅជាដើរក្នុងផ្លូវនៃសេចក្តីវិនាសវិញ ។

-បុគ្គលដែលត្រូវសេចក្តីក្រោធគ្របសង្កត់ តែងដើរទៅក្នុងផ្លូវនៃការវិនាសទ្រព្យ ។

-បុគ្គលដែលត្រូវសេចក្តីក្រោធគ្របសង្កត់ តែងដើរទៅក្នុងផ្លូវនៃការវិនាសយស ។

-ញាតិមិត្តទាំងឡាយ រមែងគេចចេញពីមនុស្សដែលត្រូវសេចក្តីក្រោធគ្របសង្កត់ ។

-បុគ្គលក្រោធ រមែងមិនឃើញធម៌ រមែងមិនដឹងប្រយោជន៍ មិនដឹងហេតុផល ។

-បុគ្គលដែលត្រូវសេចក្តីក្រោធគ្របសង្កត់ហើយ មិនមានសល់អ្វីដែលជាទីពឹងឡើយ ។

-៣៨-

-បុគ្គលក្រោធ ហ៊ានសម្លាប់សូម្បីតែមាតាបង្កើតរបស់ខ្លួន ។

-សេចក្តីក្រោធជាប្រធាននៃសេចក្តីវិនាស ។

-បុគ្គលក្រោធរមែងដេកជាទុក្ខ ។

-បុគ្គលក្រោធរមែងនិយាយច្រើន ។

-បុគ្គលក្រោធរមែងនិយាយអាក្រក់ ។

-ឈ្នះសេចក្តីក្រោធបានដោយការមិនក្រោធ ។

-ឈ្នះខ្លួនឯងប្រសើរជាង ។

-បុគ្គលមិនក្រោធតបចំពោះអ្នកដែលក្រោធហើយ ឈ្មោះថាឈ្នះសង្គ្រាមដែលគេឈ្នះបានដោយកម្រ ។

-បុគ្គលណាដឹងថាអ្នកដទៃក្រោធហើយ មានសតិស្ងប់រម្ងាប់ បុគ្គលនោះឈ្មោះថាបានបំពេញនូវប្រយោជន៍ទាំងពីរ គឺប្រយោជន៍ខ្លួនឯង និងប្រយោជន៍អ្នកដទៃ។

-ចិត្តនៃបុគ្គលក្រោធ ប្រៀបដូចជាដំបៅ ។

-បុគ្គលអ្នកក្រោធច្រើន ដូចរណ្តៅលាមកដែលគេចាក់ទឹកហើយកូរវឹក បុគ្គលនោះគេមិនគួរសេពគប់ទេ ។

-៣៩-

-បុគ្គលដែលត្រូវសេចក្តីក្រោធគ្របសង្កត់ រមែងលះបង់ចោលនូវកុសលធម៌ ។

-គប្បីលះកាត់នូវសេចក្តីក្រោធដោយបញ្ញា ។

-អំណត់គឺសេចក្តីអត់ធន់ជាគ្រឿងដុតបង់នូវបាប។

-បុគ្គលណាធ្វើបាបដោយខ្លួនឯង បុគ្គលនោះរមែង សៅហ្មងដោយខ្លួនឯង ។

-បុគ្គលណាមិនធ្វើបាបដោយខ្លួនឯង បុគ្គលនោះ រមែងមិនសៅហ្មងដោយខ្លួនឯង ។

-សៅហ្មងឬមិនសៅហ្មងជារបស់ចំពោះខ្លួន ។

-អ្នកដទៃមិនអាចញុំាងអ្នកដទៃឱ្យបរិសុទ្ធបានទេ ។

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈

( វិធីរម្ងាប់សេចក្តីក្រោធក្នុងសៀវភៅនេះ ដកស្រង់ដោយច្រើនពី **គម្ពីរវិសុទ្ធិមគ្គ** ត្រង់មេត្តាព្រហ្មវិហារនិទ្ទេស សូមពុទ្ធបរិស័ទនាំយកទៅបដិបត្តិឱ្យកើតប្រយោជន៍ផងចុះ ) ។

## អានិសង្ស[៤០]នៃការរម្ងាប់សេចក្តីក្រោធ

ព្រះសាស្តា កាលដែលព្រះអង្គគង់ប្រថាប់នៅ អគ្គាឡវចេតិយ ទ្រង់ប្រារព្ធទេវតាមួយអង្គដែលមានបញ្ហា ជាមួយភិក្ខុមួយរូប ព្រះអង្គទ្រង់ត្រាស់នូវព្រះធម៌ទេសនា នេះថា « **យោ វេ ឧប្បតិតំ កោធំ** » ជាដើម ។

### ភិក្ខុកាប់ដើមឈើដែលទេវតាអាស្រ័យនៅ

សេចក្តីពិស្តារថា កាលព្រះសាស្តាទ្រង់អនុញ្ញាតនូវសេនាសនៈដល់ភិក្ខុសង្ឃហើយ និងកាលសេនាសនៈទាំងឡាយ ដែលគ្រហស្ថទាំងឡាយ មានសេដ្ឋីក្នុងក្រុងរាជគ្រឹះជាដើម កំពុងចាត់ចែងឱ្យគេធ្វើ ក្នុងកាលនោះ មានភិក្ខុអ្នកស្រុកអាឡវីមួយអង្គ បានសាងនូវសេនាសនៈរបស់ខ្លួន ។

ភិក្ខុមួយអង្គនោះ បានឃើញដើមឈើមួយដើម ដែលធ្វើឱ្យលោកពេញចិត្ត-៤៧-នៅពេលដែលលោករៀបចំនឹងកាប់ដើមឈើនោះ ស្រាប់តែទេវតាមានកូនតូចមួយអង្គ ដែលអាស្រ័យនៅនឹងដើមឈើនោះឯង ជាកន្លែង

ដែលទេវរាជក្នុងឋានចាតុម្មហារាជិកា អនុញ្ញាតឱ្យនៅ បានពកូននឹងចង្កេះមកឈរអង្វរភិក្ខុអង្គនោះថា « បពិត្រ ព្រះគុណម្ចាស់ សូមព្រះគុណម្ចាស់កុំកាប់វិមានរបស់ខ្ញុំ ម្ចាស់ឡើយ ព្រោះខ្ញុំម្ចាស់មិនអាចពកូនដើររសាត់អណ្តែត ដោយមិនមានទីកន្លែងនៅនោះទេ » ។

ភិក្ខុគិតថា « យើងមិនអាចនឹងរកនូវដើមឈើ ផ្សេង ឱ្យបានល្អដូចដើមឈើនេះឡើយ » ទើបលោកមិន អើពើនឹងពាក្យអង្វររបស់ទេវតា ។

ទេវតាគិតថា « ភិក្ខុនេះឃើញទារកហើយ នឹង ឈប់កាប់ជាពិតប្រាកដ » ទើបយកកូនទៅដាក់នៅនឹង មែកឈើត្រង់កន្លែងដែលភិក្ខុត្រូវកាប់ ទាំងដែលលោក កំពុងតែយារពូថៅដើម្បីនឹងកាប់ទៅហើយនោះ ។

ចំណែកភិក្ខុកាលដែលលោកបានយារពូថៅ ដើម្បី នឹងកាប់ទៅហើយ លោកមិនអាចបញ្ឈប់នូវពូថៅនោះ បានឡើយ ក៏ធ្វើឱ្យដាច់ដៃកូនទេវតា នោះទៅ ។



ទេវតាកើតសេចក្តីក្រោធយ៉ាងខ្លាំង បានលើកដៃ ទាំងពីរឡើងដោយចេតនាថា « អញនឹងទះភិក្ខុនេះឱ្យ ស្លាប់ » តែភ្លាមនោះ ក៏បានគិតយ៉ាងនេះថា « ភិក្ខុនេះ ជាអ្នកមានសីល បើយើងសម្លាប់លោកទៅ យើងត្រូវធ្លាក់ នរក ឯទេវតាដទៃទៀត កាលបានជួបភិក្ខុទាំងឡាយណា កាប់ដើមឈើរបស់ខ្លួនហើយ នឹងយកយើងជាគំរូ រួច ហើយនឹងសម្លាប់ភិក្ខុទាំងឡាយនោះ » ។

បានស្តាប់មកថា នៅព្រៃហិមពាន្ត មានការប្រជុំ ទេវតា រាល់៧ថ្ងៃបក្ស ។ ក្នុងព្រៃហិមពាន្តនោះ ពួកទេវតា រមែងសួរនូវរុក្ខធម៌ថា អ្នកតាំងនៅ ឬមិនតាំងនៅក្នុងរុក្ខ-ធម៌ ។ ឈ្មោះថា « រុក្ខធម៌ » បានដល់ ការដែលរុក្ខ-ទេវតាមិនប្រទូសរ៉ាយតាមផ្លូវចិត្ត នៅពេលដែលដើមឈើ ជាលំនៅរបស់ខ្លួនត្រូវកាប់ ។ បណ្តាទេវតាទាំងនោះ ទេវតាអង្គណាមិនតាំងនៅក្នុងរុក្ខធម៌ទេ ទេវតាអង្គនោះ ត្រូវគេបណ្តេញមិនឱ្យចូលរួមក្នុងអង្គប្រជុំឡើយ ។

ទេវតាអង្គនេះឯង បានពិចារណាឃើញទោសក្នុងការមិនតាំងនៅក្នុងរុក្ខធម៌ ហើយបានរលឹកដល់បុញ្ញចរិយា ក្នុងកាលដែលព្រះតថាគតសោយព្រះជាតិជាដំរីឆទ្ទន្តជាដើម ដោយក្រសែនៃព្រះធម៌ទេសនា តាមដែលខ្លួនធ្លាប់បានស្តាប់មកអំពីព្រះភ័ក្ត្រនៃព្រះដ៏មានព្រះភាគ ។

ទេវតាអង្គនេះបានគិតជាបន្តទៀតថា « ភិក្ខុនេះមានបិតា យើងនឹងក្រាបទូលនូវរឿងនេះដល់បិតារបស់លោក » បានដាក់ដៃចុះហើយ រួចស្រែកយំទៅកាន់សំណាក់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តាហើយ បានឈរនៅក្នុងទីមួយដ៏សមគួរ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងទេវតាអង្គនេះថា « តើយ៉ាងដូចម្តេចហ្នឹង ទេវតា ? »

ទេវតាក៏បានក្រាបទូលថា « បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុអង្គនោះបានធ្វើកម្មដូចនេះ ខ្ញុំព្រះអង្គម្ចាស់ប្រាថ្នានឹងសម្លាប់លោក ប៉ុន្តែខ្ញុំព្រះអង្គម្ចាស់បានគិតនូវសេចក្តីដូចនេះ ទើបមិនសម្លាប់លោកទៅវិញ ហើយក៏

-៤៤-

ប្រញាប់មកកាន់ទីនេះ » ទេវតាបានក្រាបទូលរឿងនោះទាំងអស់ដោយពិស្តារចំពោះព្រះដ៏មានព្រះភាគ ។

ព្រះសាស្តាទ្រង់ព្រះសណ្តាប់រឿងនោះហើយ ព្រះអង្គត្រាស់ថា « សាធុ ! សាធុ ! ប្រពៃហើយទេវតា ត្រង់ដែលអ្នកគ្របសង្កត់នូវសេចក្តីក្រោធ ដែលកើតឡើងយ៉ាងនោះបាន ប្រៀបដូចជាគេបញ្ឈប់បាននូវរថ ដែលកំពុងតែលឿនទៅមុខដូច្នោះឯង » ។

ព្រះអង្គបានត្រាស់ដូច្នេះហើយ ទើបទ្រង់សម្តែងនូវព្រះគាថាជាបន្ត :

**យោ វេ ឧប្បតិតំ កោធំ  រថំ ភន្តំវ ធារយេ**
**តមហំ សារថឹ ព្រូមិ  រស្មិគ្គាហោ ឥតរោ ជនោ ។**

នរជនណា ហាមនូវសេចក្តីក្រោធ ដែលកើតឡើងហើយបាន ដូចជានាយសារថីបញ្ឈប់រថដែលកំពុងតែឆ្ពោះទៅមុខបានយ៉ាងនោះឯង តថាគតហៅនរជននោះ

-៤៥-

ថាជា **សារថី** ជនក្រៅពីនេះគ្រាន់តែជាអ្នកកាន់នូវខ្សែបង្ហៀរប៉ុណ្ណោះឯង ។

## ពន្យល់សេចក្តី

បណ្តាបទទាំងនោះ បទថា **ឧប្បតិតំ** បានដល់ដែលកើតឡើងហើយ ។

ពីរបទថា **រថំ ភន្តំវ** ដោយសេចក្តីថា ដូចយ៉ាងនាយសារថីដែលឆ្លាត បញ្ឈប់រថដែលកំពុងតែស្ទុះទៅយ៉ាងលឿនឱ្យឈប់បានតាមសេចក្តីប្រាថ្នា យ៉ាងណាមិញ បុគ្គលណា អាចសង្កត់នូវសេចក្តីក្រោធ ដែលកើតឡើងបាន ក៏យ៉ាងនោះដែរ ។

បទថា **តមហំ** ដោយសេចក្តីថា តថាគតហៅបុគ្គលនោះថា ជា **សារថី** ។

ពីរបទថា **ឥតរោ ជនោ** ដោយសេចក្តីថា ចំណែកជនក្រៅអំពីនេះ គឺសារថីរថរបស់ឥស្សរជនមានព្រះរាជានិងឧបរាជជាដើម រមែងមានឈ្មោះត្រឹមតែថា



ជាអ្នកកាន់ខ្សែបង្ហៀរប៉ុណ្ណោះ មិនមែនជាសារថីដ៏ប៉ិនប្រសប់ឡើយ ។

កាលចប់ធម៌ទេសនា ទេវតាក៏បានតាំងនៅក្នុងសោតាបត្តិផល ។ ព្រះធម៌ទេសនាបាននូវប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

ចំណែកទេវតា បានក្រាបទូលព្រះដ៏មានព្រះភាគអំពីការដែលខ្លួនមិនមានកន្លែងនៅ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រួតមើលនូវស្ថានទីរបស់ទេវតាអង្គនេះ ។ ព្រះអង្គទ្រង់បានទតឃើញស្ថានទីដ៏សមគួរមួយ ទើបព្រះអង្គត្រាស់ទៅកាន់ទេវតាថា : « នែ ! ទេវតាដ៏ចម្រើន មានដើមឈើមួយដើមនៅជិតព្រះគន្ធកុដិនាវត្តជេតពន ដែលទេវតាជាម្ចាស់បានចុតិទៅហើយកាលពីថ្ងៃមុន ដូច្នេះដើមឈើនោះនៅទំនេរ អ្នកចូរទៅស្ថិតនៅនឹងដើមឈើនោះចុះ » ។

ចាប់តាំងពីពេលនោះមក ដោយទេវតាអង្គនោះបាននូវការគ្រប់គ្រងអំពីព្រះសម្មាសម្ពុទ្ធជាអង្គម្ចាស់ ក៏បាន

ជាឧបដ្ឋាយិកាដ៏ល្អរបស់ព្រះសម្មាសម្ពុទ្ធ ។

ក្នុងពេលដែលមានទេវសមាគម ទេវតាដែលមានស័ក្តិធំទាំងឡាយយាងមក ទេវតាដទៃដែលមានស័ក្តិតូចរមែងថយទៅរហូតដល់មហាសមុទ្រ និងភ្នំចក្រវាឡ ។ ចំណែកទេវតាអង្គនេះអង្គុយស្តាប់ធម៌ក្នុងលំនៅរបស់ខ្លួនហ្នឹងឯង ។ ទេវតាអង្គនេះអង្គុយស្តាប់បញ្ហាទាំងអស់ក្នុងវិមានរបស់ខ្លួន ទោះបីជាពួកភិក្ខុសួរក្នុងបឋមយាមនៃរាត្រីក្តី ទោះបីជាពួកទេវតាសួរក្នុងវេលាមជ្ឈិមយាមនៃរាត្រីក្តី។ សូម្បីស្តេចមហារាជទាំង ៤ ក្នុងឋានចាតុម្មហា-រាជិកា យាងមកកាន់ទីទំនុកបម្រុងព្រះដ៏មានព្រះភាគ កាលដែលត្រូវយាងត្រឡប់ទៅវិញ ក៏បានសំណេះសំ-ណាលគួរសមជាមួយនឹងទេវតាអង្គនេះដែរ ហើយទើបស្តេចយាងទៅ ។ ទោះជាទេវតាដែលមានស័ក្តិធំដទៃៗទៀត កាលដែលបានជ្រាបថា «វិមានរបស់ទេវតានេះគឺព្រះដ៏មានព្រះភាគជាអង្គម្ចាស់ទ្រង់ប្រទាន » ដូច្នេះក៏

-៤៨-

រមែងតែងតែគួរសមជាមួយនឹងទេវតាអង្គនេះជានិច្ច ។

ព្រះសាស្តាទ្រង់ធ្វើរឿងនេះ ឱ្យជាហេតុកើតឡើង ហើយ ទ្រង់ក៏បញ្ញត្តនូវភូតគាមសិក្ខាបទដល់ភិក្ខុទាំងឡាយ ដូច្នេះថា ភិក្ខុធ្វើភូតគាមឱ្យវិនាស ត្រូវអាបត្តិបាចិត្តិយ ។

**(ស្រង់ចាកអដ្ឋកថាព្រះធម្មបទ កោធវគ្គ**

**និង អដ្ឋកថាព្រះវិន័យ ភូតគាមសិក្ខាបទទី១ )**

≈≈≈≈≈≈≈≈≈≈≈≈≈≈

**អនុបុព្វេន មេធាវី ថោកំ ថោកំ ខណេ ខណេ**

**កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។**

អ្នកមានប្រាជ្ញាគួរកម្ចាត់មន្ទិលរបស់ខ្លួន ជាខណៈៗ បន្តិចម្តងៗ ដោយលំដាប់ទៅ ដូចជាងមាសដែលជម្រះស្នឹមនៃមាសប្រាក់ដូច្នោះឯង ។

## វិធីរម្ងាប់សេចក្តីក្រោធ

## សមគួរដល់ការអានត្រឹមតែប៉ុណ្ណោះ

-៤៩-

## ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌
## ព្រះពុទ្ធសាសនា
## ដោយសហគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត-ក្រុង | វេលាផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| រាជធានីភ្នំពេញ | -05h00 mn.<br>-18h00 mn.<br>-19h00 mn.<br>-19h30 mn.<br>-20h00 mn.<br>-20h30 mn. | -FM 99 MHz.<br>-FM 95 MHz.<br>-AM 918 MHz.<br>-FM 97 MHz.<br>-FM 98 MHz.<br>-FM 96 MHz. |
| ក្រុងព្រះសីហនុ | -06h00 mn.<br>-13h00 mn. | -FM 92 MHz. |
| ខេត្តបាត់ដំបង | -06h00 mn.<br>-06h30 mn.<br>-18h00 mn.<br>-18h30 mn.<br>-19h30 mn. | -FM103.2MHz.<br>-FM 96 MHz.<br>-FM 91 MHz.<br>-FM 96 MHz.<br>-FM103.2MHz. |
| ក្រុងប៉ៃលិន | -18h00 mn. | -FM 90.5MHz. |
| ខេត្តសៀមរាប | -18h30 mn. | -FM100.5MHz. |
| ខេត្តពោធិ៍សាត់ | -06h00 mn. | -FM 98.5MHz. |
| ខេត្តកំពត | -18h30 mn. | -FM103.5MHz. |
| ខេត្តកំពង់ចាម | -05h30 mn. | -FM100.5MHz. |
| ខេត្តព្រះវិហារ | -18h30 mn. | -FM 99 MHz. |



## សៀវភៅដែលរៀបរៀងដោយ
### ខ្ញុំព្រះករុណា - ខ្ញុំបាទ
### ✍ ប៊ុត_សាវង្ស ✍

១. វិធីរម្ងាប់សេចក្ដីក្រោធ
២. ជំនួយសតិភាគ ១ ដល់ភាគ ៨
៣. មនុស្សជាមួយនឹងការងារ
៤. សិក្ខាបទមនុស្សល្អ
៥. ពរ៤ប្រការ
៦. ព្រះពុទ្ធភាសិត ៤៣ គាថា
៧. ខ្លឹមសារគួរយល់ដឹង
៨. ព្រះពុទ្ធសាសនា
៩. កូនមាសឪពុក
១០. ម៉ែ

**សព្វទានំ ធម្មទានំ ជិនាតិ**

ធម្មទានឈ្នះអស់ទានទាំងពួង ។

# សារបណ្ណ

-៧០-

**ល.រ.** **ទំព័រ**


☆ -សេចក្តីផ្តើម ......................................១

១-ពិចារណាដល់ភាពសៅហ្មងនៃបុគ្គលក្រោធ........៤

២-ពិចារណាទោសនៃសេចក្តីក្រោធ ................. ៦

៣-ពិចារណាដល់សេចក្តីល្អរបស់គេ...................៩

៤-ពិចារណាថា ជាការដាក់ទោសខ្លួនឯង.......... ១១

៥-ពិចារណាថា យើងក្រោធគឺសាងទុក្ខឱ្យខ្លួនឯង...១៣

៦-ពិចារណាថា សត្វមានកម្មជារបស់ខ្លួន ...........១៦

៧-ពិចារណាបុព្វចរិយារបស់ព្រះពុទ្ធជាអង្គម្ចាស់... ១៨

៨-ពិចារណាញាតិក្នុងសង្សារវដ្ត ....................២៥

៩-ពិចារណាអានិសង្សរបស់មេត្តា .................២៧

១០-ពិចារណាដោយវិធីចែកធាតុ ....................៣១

១១-ពិចារណាហេតុផល និងបដិបត្តិក្នុងការឱ្យទាន...៣៤

១២-ពិចារណាតាមសេចក្តីនៃព្រះពុទ្ធភាសិត..........៣៧

☆ -អានិសង្សនៃការរម្ងាប់សេចក្តីក្រោធ ............ ៤១


ទីបញ្ចប់សេចក្តីក្រោធ